ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 17 / 01 / 2011
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ:០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
Case File/Dossier N° 002/19-09-2007/ECCC/TC

ចំពោះមុខ:
ចៅក្រម **និល ណុន** ជាប្រធាន
ចៅក្រម **Silvia CARTWRIGHT**
ចៅក្រម **យ៉ា សុខន**
ចៅក្រម **Jean-Marc LAVERGNE**
ចៅក្រម **ធូ មណី**

កាលបរិច្ឆេទ: ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១
ភាសាដើម: ខ្មែរ/អង់គ្លេស/បារាំង
ចំណាត់ថ្នាក់ឯកសារ: សាធារណៈ

---

# ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ

---

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY

**ជនជាប់ចោទ**
នួន ជា
អៀង សារី
អៀង ធីរិទ្ធ
ខៀវ សំផន

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ពេជ អង្គ
Elisabeth SIMONNEAU FORT

**មេធាវីជនជាប់ចោទ**
សុន អរុណ
Michiel PESTMAN
Victor KOPPE
អាង ឧត្តម
Michael G. KARNAVAS
ផាត់ ពៅសៀង
Diana ELLIS
សា សុវ៉ាន
Jaques VERGÈS
Philippe GRÉCIANO

**អង្គជំនុំជម្រះសាលាដំបូង** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

**ក្រោយពីបានទទួល** សំណុំរឿងលេខ ០០២/១៩ កញ្ញា ២០០៧/អវតក អនុលោមតាមសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី អៀង ធីរិទ្ធ នួន ជា និង ខៀវ សំផន ប្រឆាំងនឹងដីកាដំណើស្រាយ[1] ដែលបានចេញដោយអង្គបុរេជំនុំជម្រះ នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ។

**អនុលោមតាម** វិធាន ២៣, ២៤, ២៩, ៣១, ៧៩, ៨០, ៨០*ស្ទួន*, ៨៤, ៨៥, ៨៧, ៨៩, ៩១*ស្ទួន*, នៃវិធានផ្ទៃក្នុង ("វិធាន") ។

## ហេតុដូច្នេះសម្រេច

**បង្គាប់ឲ្យ** ភាគីដាក់ឯកសារដូចខាងក្រោមនេះ៖

I. <u>បញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលខ្លួនមានបំណងស្នើសុំឲ្យកោះហៅ ហើយដែលអ្នកទាំងនោះមិនបានស្នើសុំនូវវិធានការការពារ</u>

១. ចំពោះសាក្សី និងអ្នកជំនាញដែលបានសម្រេចដោយសហចៅក្រមស៊ើបអង្កេតរួចហើយ ព្រមទាំងដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានប្រកាសទទួលស្គាល់ដោយសហចៅក្រមស៊ើបអង្កេត ឬអ្នកដែលត្រូវបានស្នើសុំដើម្បីស្តាប់ចម្លើយជាលើកដំបូងនៅក្នុងតុលាការ **ដែលអ្នកទាំងនោះមិនបានស្នើសុំនូវវិធានការការពារ៖**

ក. បញ្ជីឈ្មោះសាក្សីដែលខ្លួនមានបំណងស្នើសុំឲ្យកោះហៅ

ខ. បញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណី ដែលខ្លួនមានបំណងស្នើសុំឲ្យកោះហៅដើម្បីមកធ្វើសេចក្តីថ្លែងការណ៍ក្នុងពេលសវនាការ ដោយធ្វើការបែងចែកជាពីរ គឺអ្នកមកធ្វើសេចក្តីថ្លែងការណ៍

---

[1] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/1/26 ។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/2/12។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/4/14។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការសម្រេចបន្តថិរវេលានៃការឃុំខ្លួនគាត់បណ្តោះអាសន្ននៅក្នុងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/5/9 ។



TRIAL CHAMBER CHAMBRE DE PR... E C C C E T

ទៅលើអង្គហេតុ និង/ឬអ្នកមកធ្វើសេចក្តីថ្លែងការណ៍ទាក់ទងនឹងផលប៉ះពាល់ទៅនឹងបទល្មើស ដែលបានចោទប្រកាន់ ។

គ. បញ្ជីឈ្មោះអ្នកជំនាញដែលខ្លួនមានបំណងស្នើសុំឲ្យកោះហៅ

២. បញ្ជីទាំងនេះត្រូវដាក់ក្នុងរយៈពេលដូចដែលមានចែងក្នុងបទប្បញ្ញត្តិនៃវិធាន ៨០ (១) និង (២) នៃវិធានផ្ទៃក្នុង ។ រយៈពេលកំណត់នេះត្រូវចាប់គិតពីថ្ងៃសុក្រ ទី ១៤ ខែ មករា ឆ្នាំ ២០១១ ជាថ្ងៃដែលក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូងបានទទួលសំណុំរឿងជាផ្លូវការពីអង្គបុរេជំនុំជម្រះ។ ដោយសារបញ្ហានៃការបកប្រែភាសា ដូចដែលបានជូនដំណឹងមកអង្គជំនុំជម្រះ បញ្ជីទាំងនេះត្រូវដាក់យ៉ាងហោចណាស់ជាភាសាខ្មែរ និង ភាសាអង់គ្លេស ឬភាសាបារាំង ប៉ុន្តែភាគីត្រូវដាក់នូវភាសាដែលមិនទាន់ដាក់ក្នុងរយៈពេលដ៏ឆាប់បំផុតដែលអាចធ្វើបាន។ ជាការអនុវត្ត បញ្ជីដែលទាក់ទងទៅនឹងសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញនីមួយៗត្រូវមានព័ត៌មានដូចខាងក្រោម៖

ក. នាមត្រកូល និងនាមខ្លួន ភេទ ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត ។

ខ. អាសយដ្ឋានបច្ចុប្បន្ន និង/ឬ ព័ត៌មានលំអិតសម្រាប់ទំនាក់ទំនង ។

គ. លេខឯកសារយោងនៃកំណត់ហេតុស្តាប់ចម្លើយ ឬឯកសារពាក់ព័ន្ធផ្សេងៗ ។

ឃ. វិធានការការពារដែលមានជាធរមាន ព្រមទាំងឯកសារដែលជាសេចក្តីសម្រេចទាក់ទងនឹងវិធានការការពារទាំងនោះ ។

ង. សេចក្តីអះអាងដែលបញ្ជាក់ពីទំនាក់ទំនងញាតិ ដូចដែលមានចែងក្នុងបទប្បញ្ញត្តិនៃវិធាន២៤(២) ។

ច. ការប៉ាន់ស្មាននូវរយៈពេលសម្រាប់ធ្វើសក្ខីកម្ម ។

ឆ. ភាសាដែលប្រើប្រាស់សម្រាប់ធ្វើសក្ខីកម្ម ។ និង

ជ. ប្រភេទនៃសម្បថដែលត្រូវធ្វើ ។

៣. បញ្ជីឈ្មោះ សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ទាំងនោះត្រូវដាក់ជាឯកសារ "សម្ងាត់" រហូតដល់មានសេចក្តីសម្រេចជាចុងក្រោយពីអង្គជំនុំជម្រះអំពីការធ្វើចំណាត់ថ្នាក់លើឯកសារទាំងនោះ ។ អង្គជំនុំជម្រះនឹងបញ្ជូនបញ្ជីទាំងនោះទៅអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងរយៈពេលមួយសមស្រប ដើម្បីត្រៀមរៀបចំសវនាការ ។

៤. បញ្ជីទាំងនេះត្រូវរៀបចំក្នុងទម្រង់ជាតារាង ដូចទៅនឹងឯកសារគំរូដែលបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងដីកានេះ។ ក្រឡាបញ្ជីនៃអង្គជំនុំជម្រះនឹងផ្តល់ជូនដល់ភាគីនូវឯកសារគំរូទាំងនេះជាទម្រង់ Microsoft Word ។ ភាគីក៏ត្រូវផ្តល់ជូនផងដែរនូវបញ្ជីទាំងនេះជាទម្រង់ Microsoft Word ដល់ក្រឡាបញ្ជីនៃអង្គជំនុំជម្រះក្នុងរយៈពេលមួយសមស្របសំរាប់អង្គជំនុំជម្រះ ប្រើប្រាស់ជាលក្ខណៈផ្ទៃក្នុង ។

II. <u>បញ្ជីឈ្មោះសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីថ្មី ដែលស្នើសុំវិធានការការពារ</u>

៥. ប្រសិនបើមានសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីថ្មី ដែលភាគីមានបំណងស្នើសុំឲ្យកោះហៅ ហើយដែលអ្នកទាំងនោះមានបំណងស្នើសុំនូវវិធានការការពារ ការស្នើសុំវិធានការនេះត្រូវដាក់ជាបីភាសាក្នុងរយៈពេលដូចដែលមានចែងតាមបទប្បញ្ញត្តិនៃវិធាន ៨០ (១) និង (២) នៃវិធានផ្ទៃក្នុង ។ រហូតដល់មានសេចក្តីសម្រេចពីអង្គជំនុំជម្រះលើសំណើសុំវិធានការការពារនេះ បញ្ជីឈ្មោះសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីនេះត្រូវដាក់ជាឯកសារ "សម្ងាត់បំផុត" ។ ជាការអនុវត្ត បញ្ជីនេះត្រូវមាននូវព័ត៌មានដែលទាក់ទងនឹងសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗ ដូចទៅនឹងអ្វីដែលបានកំណត់ក្នុងកថាខណ្ឌទី២ (ក-ជ) ខាងលើ ។ បន្ទាប់ពីបានសម្រេចលើសំណើសុំនូវវិធានការការពារនេះ អង្គជំនុំជម្រះសាលាដំបូងនឹងផ្តល់ឱកាសដល់ភាគីដើម្បីផ្តល់យោបល់លើបញ្ជីទាំងនេះ ។

III. <u>ព័ត៌មានដែលតម្រូវឲ្យមានទាក់ទងទៅនឹងសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ</u>

៦. បន្ថែមទៅលើបញ្ជីឈ្មោះ សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ភាគីត្រូវផ្តល់ផងដែរដោយមិនឲ្យលើសពីថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១ នូវ ៖

ក. សេចក្តីសង្ខេបនៃអង្គហេតុ ដែលសាក្សីនឹងត្រូវធ្វើសក្ខីកម្ម ឬសេចក្តីសង្ខេបអង្គហេតុដែលដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗនឹងមកធ្វើសេចក្តីថ្លែងការណ៍ ឬអង្គហេតុដែលមានផលប៉ះពាល់ទៅនឹងបទចោទនីមួយៗ។ ដោយវិធានការការពារអាចត្រូវដាក់ចេញ ឬដោយមិនទាន់បានពិចារណាដោយអង្គជំនុំជម្រះ សេចក្តីសង្ខេបនោះត្រូវមាននូវភាពលម្អិតគ្រប់គ្រាន់ដែលអាចឲ្យអង្គជំនុំជម្រះ និងភាគីអាចយល់បានពេញលេញនូវលក្ខណៈ និង ខ្លឹមសារនៃសក្ខីកម្មដែលបានស្នើសុំនោះ ។

ខ. សេចក្តីសង្ខេបអំពីភាពជំនាញរបស់អ្នកជំនាញ និងគុណគុណវុឌ្ឍិរបស់អ្នកជំនាញនីមួយៗដែលបានស្នើសុំ ។ ដោយវិធានការការពារអាចត្រូវដាក់ចេញ សេចក្តីសង្ខេបនេះត្រូវមាននូវ



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E.C.C.C. E.T.C.

ភាពលម្អិតគ្រប់គ្រាន់ដែលអាចឱ្យអង្គជំនុំជម្រះ ឬភាគីអាចយល់បានពេញលេញនូវលក្ខណៈ និងខ្លឹមសារនៃភាពជំនាញរបស់អ្នកជំនាញដែលបានស្នើសុំនោះ ។

គ. ចំណុចនៃការចោទប្រកាន់ ដែលសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកជំនាញដែលបានស្នើសុំនោះ រំពឹងថានឹងមកផ្តល់សក្ខីកម្ម ហើយត្រូវបញ្ជាក់ផងដែរនូវលេខកថាខណ្ឌនៃដីកាដំណោះស្រាយ និងបទចោទជាក់លាក់ណាមួយ។ ការសង្ខេបនេះត្រូវចង្អុលបង្ហាញឱ្យបានច្បាស់លាស់នូវទំនាក់ទំនងរវាងសក្ខីកម្មរបស់សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីដែលបានស្នើសុំនោះទៅនឹងអង្គហេតុនានាដែលត្រូវបញ្ជាក់ដោយភស្តុតាងក្នុងពេលសវនាការ ហើយដើម្បីឱ្យកាន់តែច្បាស់ ឯកសារគំរូនៃការសង្ខេបនេះត្រូវបានភ្ជាប់ទៅនឹងដីកានេះ។ ភាគីក៏ត្រូវផ្តល់ជូនផងដែរនូវតារាងនេះជាទម្រង់ Microsoft Word ដល់ក្រឡាបញ្ជីនៃអង្គជំនុំជម្រះ សម្រាប់អង្គជំនុំជម្រះប្រើប្រាស់ជាលក្ខណៈផ្ទៃក្នុង ។ ក្នុងគោលបំណងដើម្បីជួយដល់ភាគីក្នុងការដាក់នូវសម្ភារៈដែលបានស្នើសុំ អង្គជំនុំជម្រះនឹងផ្តល់ជូនដល់ភាគីផងដែរនូវ “តារាងនៃអង្គហេតុដែលត្រូវបញ្ជាក់ដោយភស្តុតាង” ដូចដែលបានចង្អុលបង្ហាញដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ តារាងនេះគឺមិនមែនជាការកំណត់ដាច់ខាតនូវអង្គហេតុ ដែលនឹងត្រូវធ្វើការដេញដោលក្នុងពេលសវនាការនោះទេ ប៉ុន្តែវាគ្រាន់តែជាការណែនាំជួយដល់ភាគីក្នុងការរៀបចំរឿងក្តីប៉ុណ្ណោះ ។

៧. បញ្ជីនេះត្រូវដាក់ជាឯកសារ “សម្ងាត់” រហូតដល់មានសេចក្តីសម្រេចជាចុងក្រោយពីអង្គជំនុំជម្រះអំពីការធ្វើចំណាត់ថ្នាក់នៃឯកសារនេះ ។

៨. អនុវត្តតាមចំណុច II ខាងលើ ហើយដោយមិនឱ្យលើសពីថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១១ ភាគីក៏ត្រូវចង្អុលបង្ហាញផងដែរ ថាតើភាគីនីមួយៗមានបំណងជំទាស់ទៅនឹងការកោះហៅសាក្សី ឬអ្នកជំនាញដែលបានស្នើសុំដែរឬទេ ហើយត្រូវបញ្ជាក់ពីមូលហេតុនៃការជំទាស់នោះ ។ អង្គជំនុំជម្រះនឹងធ្វើការពិចារណាថាតើខ្លួនមានបំណងស្នើឱ្យភាគីដែលជំទាស់នោះដាក់នូវសារណាបន្ថែមដែរឬទេ ។

## IV. <u>បញ្ជីនៃអង្គហេតុដែលមិនមានការតវ៉ា រួមទាំងអង្គហេតុដែលបានធ្វើការវិនិច្ឆ័យរួចហើយដោយអង្គជំនុំជម្រះក្នុងសំណុំរឿង លេខ ០០១</u>

៩. ដោយមិនឱ្យលើសពីថ្ងៃ ២៥ ខែ មិនា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញា និងក្រុមមេធាវីការពារក្តីត្រូវដាក់បញ្ជីរួមគ្នានូវអង្គហេតុដែលមិនមានការតវ៉ា អនុលោមតាមវិធាន ៨០(៣) (ង)។ ភាគីនីមួយៗក៏ត្រូវបញ្ជាក់

00635752



ផងដែរ ថាតើអង្គហេតុដែលបានព្រមព្រៀងទាំងនេះមានផលប៉ះពាល់ទៅលើបញ្ជីឈ្មោះសាក្សី និងអ្នកជំនាញដែលបានស្នើសុំដែរឬទេ និងថាតើមានសាក្សី ឬអ្នកជំនាញណាខ្លះដែលខ្លួនត្រូវដកចេញពីបញ្ជី។

១០. សហព្រះរាជអាជ្ញា និងមេធាវីការពារក្តីត្រូវបន្តសហការគ្នាជាប្រចាំ ហើយត្រូវរាយការណ៍ជូនអង្គជំនុំជម្រះឱ្យបានឆាប់រហ័សអំពីអង្គហេតុ ឬអង្គហេតុដែលបញ្ជាក់ដោយភស្តុតាងណាមួយ ដែលក្រោយមកខ្លួនបានទទួលស្គាល់ថាជាអង្គហេតុមិនមានការតវ៉ា។

១១. នៅក្នុងបញ្ជីនៃអង្គហេតុដែលត្រូវបញ្ជាក់ដោយភស្តុតាង អង្គជំនុំជម្រះក៏បានចង្អុលបង្ហាញផងដែរនូវអង្គហេតុមួយចំនួនដែលទាក់ទងទៅនឹងបរិបទប្រវត្តិសាស្ត្រ ដែលបានព្រមព្រៀងរវាងសហព្រះរាជអាជ្ញា និងមេធាវីការពារក្តីនោះ អាចត្រូវបានចាត់ទុកថាបានទទួលយក ព្រោះអង្គហេតុទាំងនោះត្រូវបានអង្គជំនុំជម្រះធ្វើការវិនិច្ឆ័យរួចហើយនៅក្នុងសំណុំរឿងលេខ ០០១ ។

V. <u>បញ្ជីនៃឯកសារ និងវត្ថុតាង</u>

១២. ដោយមិនឱ្យលើសពីថ្ងៃ ១៣ ខែ មេសា ឆ្នាំ ២០១១ ភាគីក៏ត្រូវដាក់ជូនផងដែរនូវ៖

- ក. បញ្ជីឯកសារដែលមាននៅក្នុងសំណុំរឿងរួចហើយ ដែលភាគីមានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដោយត្រូវបង្ហាញនូវអត្តសញ្ញាណឱ្យបានសមស្របតាមរយៈលេខឯកសារយោង ចំណងជើង ភាសាដែលមាន ហើយត្រូវពន្យល់ដោយសង្ខេបអំពីលក្ខណៈ និងខ្លឹមសាររបស់វា ។
- ខ. បញ្ជីឯកសារថ្មី ដែលភាគីមានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដោយមានការពន្យល់ដោយសង្ខេបអំពីលក្ខណៈ និងខ្លឹមសាររបស់វា ។
- គ. "តារាងនៃភស្តុតាងជាឯកសារ" ដែលចង្អុលបង្ហាញនូវភស្តុតាងជាឯកសារ ដែលភាគីនឹងយកមកប្រើទាក់ទងនឹងការចោទប្រកាន់ដែលមាននៅក្នុងដីកាដំណោះស្រាយ ចំពោះអង្គហេតុដែលត្រូវបញ្ជាក់ដោយភស្តុតាងនីមួយៗ ។

១៣. សម្ភារៈទាំងនេះត្រូវដាក់ជាឯកសារ "សម្ងាត់" រហូតដល់មានសេចក្តីសម្រេចជាចុងក្រោយពីអង្គជំនុំជម្រះអំពីការធ្វើចំណាត់ថ្នាក់លើឯកសារទាំងនោះ និងត្រូវដាក់ក្នុងទម្រង់ជាតារាង ដូចដែលបានបង្ហាញដោយឯកសារគំរូដែលបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងដីកានេះ។ ភាគីនីមួយៗក៏ត្រូវផ្តល់ជូនផងដែរនូវបញ្ជីសម្ភារៈទាំងនោះជាទម្រង់ Microsoft Word ដល់ក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូង សម្រាប់អង្គជំនុំជម្រះប្រើប្រាស់ជាលក្ខណៈផ្ទៃក្នុង ។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C E T C

១៤. ដោយមិនឱ្យលើសពីថ្ងៃ ១៣ ខែ មេសា ឆ្នាំ ២០១១ ភាគីត្រូវដាក់ជូននូវបញ្ជីវត្ថុតាង ដែលខ្លួនមានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដោយមានការពន្យល់សង្ខេបអំពីលក្ខណៈ និងខ្លឹមសាររបស់វា ព្រមទាំងលេខឯកសារយោងទាំងនេះផងដែរ។ បញ្ជីនេះត្រូវដាក់ជាឯកសារ "សម្ងាត់" រហូតដល់មានសេចក្តីសម្រេចជាចុងក្រោយពីអង្គជំនុំជម្រះអំពីការធ្វើចំណាត់ថ្នាក់លើឯកសារទាំងនោះ។ បញ្ជីត្រូវដាក់នៅក្នុងទម្រង់ជាតារាងផ្អែកតាមឯកសារគំរូដែលបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងដីកានេះ។ ភាគីនីមួយៗក៏ត្រូវផ្តល់ជូនផងដែរនូវបញ្ជីជាទម្រង់ Microsoft Word ដល់ក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូង សម្រាប់អង្គជំនុំជម្រះប្រើប្រាស់ជាលក្ខណៈផ្ទៃក្នុង ។

## VI. <u>ការបង្ហាញអំពីបញ្ហាអង្គច្បាប់ផ្សេងៗមុនពេលសវនាការបឋម</u>

១៥. ដោយមិនឱ្យលើសពីថ្ងៃ ១៣ ខែ មេសា ឆ្នាំ ២០១១ ភាគីត្រូវបង្ហាញនូវបញ្ហាអង្គច្បាប់ផ្សេងៗដែលខ្លួនមានបំណងលើកឡើងនៅក្នុងសវនាការបឋម។

ភ្នំពេញ ថ្ងៃទី១៧ ខែ មករា ឆ្នាំ២០១១

ប្រធានអង្គជំនុំជម្រះសាលាដំបូង

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C E T C

និល ណុន